# មេរៀនទី ៨៦៖ម៉ូសេបញ្ជូនអ្នកស៊ើបការទៅកាន់ ទឹកដីសន្យា

ជនគណនា ១៣៖១-១៤៖២៣

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/qaYz56_Wlug

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/raBUuhqu4RU

**គោលបំណង៖ ព្រះអង្គមិនដែលបរាជ័យឡើយ**

**ខគម្ពីរចងចាំ៖** សុភាសិត ១៦៖៩ *"ចិត្តរបស់មនុស្សរមែងគិតសំរេចផ្លូវរបស់ខ្លួន តែគឺព្រះយេហូវ៉ាដែលទ្រង់ដំរង់ជំហានគេវិញ"។*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះអង្គទ្រង់អស្ចារ្យ https://youtu.be/QXEVqO94wpg

២. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

៣. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ការពារប៉េងប៉ោងកុំឲ្យធ្លាក់ដី»



១. សូមបែងចែកកុមារជាក្រុម ក្នុង១ក្រុមមានគ្នាពី ៣ ទៅ ៤នាក់។

២. ឲ្យប៉េងប៉ោង១ទៅកាន់ក្រុមនីមួយៗ។

៣. ពួកគេត្រូវធ្វើការជួយគ្នាធ្វើយ៉ាងណាដើម្បីរក្សាប៉េងប៉ោងកុំឲ្យធ្លាក់ដល់ដី

៤. ពេលដែលប៉េងប៉ោងប៉ះដី ពួកគេអាចអង្គុយចុះបាន។

៥. បន្ទាប់ពីប៉េងប៉ោងនៅក្នុងក្រុមនីមួយៗធ្លាក់ដល់ដីគ្រប់ក្រុមហើយ សូមរំលឹកកុមារថាមនុស្សទាំងអស់មិនគ្រប់លក្ខណ៍ទេ ហើយយើងនឹងជួបការបរាជ័យ ប៉ុន្តែព្រះមិនដែលបរាជ័យ ឡើយ។ គ្រប់អ្វីៗដែលព្រះបានធ្វើគឺទ្រង់តែងតែទទួលបានជោគជ័យ។

## ៤. ការណែនាំមេរៀន

នៅពេលដែលយើងមានបញ្ហាព្រះមិនដែលបោះបង់យើងឡើយ នៅពេលដែលយើងកើតទុក្ខ ទ្រង់មិនដែលបោះបង់យើងឡើយ ហើយព្រះមិនដែលខកខាននឹងប្រទានពរដល់យើងឡើយ។ ព្រះជាម្ចាស់ក៏បានយកចិត្តទុកដាក់ចំពោះសត្វស្លាបនៅលើអាកាស និងសួនច្បារផងដែរ។ លើសពីនេះទៅទៀតគឺព្រះអង្គយកព្រះទ័យទុកដាក់ចំពោះប្អូនៗ! នៅក្នុងព្រះគម្ពីរគឺពោរពេញទៅដោយរឿងរ៉ាវ អំពីរបៀបដែលព្រះជាម្ចាស់ ទ្រង់មិនដែលខកខាន នឹងរំដោះរាស្ត្រទ្រង់ពីស្ថានភាពដ៏គួរឲ្យភ័យខ្លាចនោះឡើយ។ នៅថ្ងៃនេះយើងនឹងរៀនអំពីរបៀបដែលម៉ូសេ បានបញ្ជូនអ្នកស៊ើបការ ១២នាក់ ទៅកាន់ទឹកដីសន្យា ដែលព្រះបានប្រទានឲ្យជនជាតិអ៊ីស្រាអែល។ សូមស្វែងយល់ជាមួយគ្នាថា តើពួកគេជ្រើសរើសទុកចិត្តលើព្រះ ដែលទ្រង់មិនដែលបរាជ័យនោះបែបយ៉ាងណា!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ទីបំផុតវាដល់ពេលដែលជនជាតិអ៊ីស្រាអែលចូលទៅទាមទារទឹកដី ដែលព្រះបានសន្យាឲ្យពួកគេហើយ។ ម៉ូសេបានបញ្ជូនអ្នកស៊ើបការមួយចំនួនដើម្បីទៅមើលទឹកដីសន្យា។ វាគឺជាទឹកដីដែលសំបូរបែបទៅតាមការសន្យារបស់ព្រះ វាសំបូរទៅដោយផ្លែឈើ ទឹកដោះ និងទឹកឃ្មុំ។ នៅពេលដែលអ្នកស៊ើបការទាំងនោះបានត្រលប់មកវិញ ពួកគេគ្រាន់តែរាយការណ៍ទៅតាមអ្វីដែលម៉ូសេបានសួរតែប៉ុណ្ណោះ។ ពួកគេបានប្រាប់ពីផលផ្លែនៃស្រុកនោះ មានមនុស្សដែលខ្លាំងពូកែ និងទីក្រុងដែលមានកំពែងការពាររឹងមាំ (**ជនគណនា ១៣៖២៦-២៩**)។

ប៉ុន្តែកាលែបមានគំនិតផ្ទុយពីអ្នកផ្សេងទៀតទៅវិញ គាត់គិតថាអ្នកស៊ើបការផ្សេងទៀតបាននិយាយហួសពីអ្វី ដែលពួកគេត្រូវបានបញ្ជូនអោយទៅធ្វើហើយ។ ពួកគេចាប់ផ្តើមត្អូញត្អែរថានឹងគ្មានវិធីណាដែលអាចយកឈ្នះ មនុស្សដែលរស់នៅលើទឹកដីនោះបានទេ គេថែមទាំងនិយាយថាមនុស្សដែលនៅទីនោះគឺជាយក្សទៀតផង។ ប្រជាជនអ៊ីស្រាអែលចាប់ផ្តើមបះបោរប្រឆាំងនឹងម៉ូសេ ហើយនឹងព្រះផងដែរ។ អាកប្ប-កិរិយា រអ៊ូរទាំរបស់ជនជាតិអ៊ីស្រាអែលបានចាប់ផ្តើមមានសារជាថ្មីឡើងវិញ។ ពួកគេបានបាត់បង់នូវសេចក្តីជំនឿ ម្តងទៀត ហើយចង់ត្រឡប់ទៅប្រទេសអេហ្ស៊ីបវិញ។

ក្រៅពីកាលែប ក៏មានយ៉ូស្វេម្នាក់ទៀតដែលបានលើកទឹកចិត្តដល់ជនជាតិអ៊ីស្រាអែលឱ្យដណ្តើមយកទឹក-ដីនេះ ដោយទទូចថាព្រះជាម្ចាស់នឹងនៅជាមួយពួកគេ។ កាលែប និងយ៉ូស្វេដឹងថាពួកគេត្រូវទុកចិត្តលើព្រះដើម្បីឲ្យទ្រង់ជួយពួកគេ។ ហើយពួកគេក៏ដឹងដែរថា ព្រះអង្គមិនដែលនឹងខកខានក្នុងការរក្សានូវសេចក្តីសន្យារបស់ទ្រង់នោះដែរ។ ដោយសារតែជនជាតិអ៊ីស្រាអែលមិនបានទុកចិត្តលើអំណាចរបស់ទ្រង់ ព្រះអង្គបានដាក់ទោសពួកគេដោយមានបន្ទូលថាក្នុងរយៈពេល ៤០ ឆ្នាំនេះ នឹងគ្មានមនុស្សពេញវ័យណាម្នាក់អាចចូលទៅកាន់ទឹកដីសន្យាបានឡើយលើកលែងតែង កាលែប និង យ៉ូស្វេតែប៉ុណ្ណោះ។

យើងត្រូវតែចងចាំជានិច្ចថាព្រះអង្គទ្រង់គ្រប់លក្ខណ៍ និង មានអំណាច។ ព្រះនឹងមិនធ្វើឲ្យយើងបរាជ័យនោះឡើយ។ គ្រប់ពេលដែលប្អូនជួបបញ្ហា ប្អូនត្រូវតែទុកចិត្តដល់ទ្រង់។ សូមចាំថាគ្មានអ្វីដែលធំជាងព្រះនោះទេ ហើយទ្រង់ក៏មិនដែលបរាជ័យដែរ។

## ៦. សំនួរពិភាក្សា

១. តើមានអ្នកស៊ើបការប៉ុន្មាននាក់ត្រូវបានបញ្ជូនអោយទៅពិនិត្យមើលទឹកដីសន្យា?
(*អ្នកស៊ើបការ ១២ នាក់*)

២. តើមានអ្នកស៊ើបការប៉ុន្មាននាក់ដែលនិយាយថាមានយក្សរស់នៅលើទឹកដីនោះ ហើយថាមនុស្សទាំងនោះ គឺខ្លាំងជាងជនជាតិអ៊ីស្រាអែល? (*អ្នកស៊ើបការ១០នាក់*)

៣. តើអ្នកស៊ើបការណាខ្លះដែលនិយាយថា ពួកគេអាចប្រយុទ្ធជាមួយនឹងយក្សនោះបាន ហើយនឹងឈ្នះដោយសារជនជាតិអ៊ីស្រាអែលមានព្រះគង់ជាមួយពួកគេ? (*កាលែប និងយ៉ូស្វេ*)

៤. តើអ្នកមានបញ្ហា(យក្ស)អ្វីខ្លះនៅក្នុងជីវិតរបស់អ្នកដែលព្រះមិនអាចជួយអ្នកអោយឈ្នះបញ្ហានោះបាន? (*បញ្ហាគ្រួសារ ទឹកជំនន់ បញ្ហារបស់មិត្តភក្តិ ។ល។*)

## ៧. ល្បែងកំសាន្ត «រៀបពែងជាជង់»



សំភារៈដែលត្រូវការ៖ ពែងមួយចំនួន

១. សូមបែងចែកកុមារជាក្រុម ហើយក្នុង១ក្រុមមានកុមារពី៣ ទៅ៤ នាក់។

២. ឲ្យពែងក្រដាសទៅកុមារ ហើយបន្ទាប់មកឲ្យកុមារតំរៀបពែងក្រដាសនោះ ជាជង់ឡើងលើ ដោយធ្វើយ៉ាងណាកុំឲ្យពែងទាំងនោះដួលឡើយ។

៣. ក្រុមណាដែលរៀបពែងជាជង់ បានខ្ពស់ជាងគេជាអ្នកឈ្នះ។

៤. បន្ទាប់ពីលែងល្បែងនេះចប់ សូមរំលឹកកុមារថា យើងទទួលបរាជ័យពីព្រោះយើងជាមនុស្ស ប៉ុន្តែព្រះនឹងមិនដែលទទួលបរាជ័យ ឡើយយើងអាចទុកចិត្តលើទ្រង់ជានិច្ចបាន។

## ៨. ខគម្ពីរចងចាំ

**សុភាសិត ១៦:៩** *" ចិត្តរបស់មនុស្សរមែងគិតសំរេចផ្លូវរបស់ខ្លួន តែគឺព្រះយេហូវ៉ាដែលទ្រង់ដំរង់ជំហានគេវិញ"* ។

## ៩. ហាត្ថកម្ម

រូបផាត់ពណ៌ **"ព្រះមិនដែលបរាជ័យឡើយ"** សូមឲ្យកុមារសរសេរឃ្លា "ព្រះមិនដែលបរាជ័យឡើយ" នៅខាងក្នុងរូបបេះដូងនៃរូបផាត់ពណ៌នៅទំព័រខាងក្រោម ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូះ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

មានមនុស្សជាច្រើនបានស្លាប់ ដោយសារពួកគេបានប្រកាសថាពួកគេមានជឿលើព្រះយេស៊ូវគ្រីស្ទ។ ខណៈពេលមនុស្សភាគច្រើនមិនធ្លាប់ជួបប្រទះនឹងការបៀតបៀនបែបនេះក្តី ក៏ធ្វើឲ្យអ្នកដែលមិនមែនជាគ្រីស្ទបរិសទ័ច្រើនអាចនឹងមិនពេញចិត្តជាមួយនឹងការអះអាងរបស់យើង ចំពោះការស្គាល់សេចក្តីពិតនៅក្នុងព្រះគ្រីស្ទ។ ការប្រឈមមុខបែបនេះធ្វើឲ្យគ្រីស្ទបរិសទ័ប្រឈមមុខនឹងស្ថានភាពលំបាក។ សូមគិតពីអ្នកដែលមិនមែនជាគ្រីស្ទបរិសទ័ហើយដែលអ្នកកំពុងតែមានទំនាក់ទំនងជាមួយពួកគេ។ តើអ្នកដែល ជាមនុស្សម្នាក់កំពុងឈរនៅចំពោះមុខកុមារៗហើយកំពុងតែបង្រៀនពួកគេនេះ ស្ថិតនៅក្នុងក្រុមមនុស្ស តែមួយជាមួយពួកគេទាំងនោះដែរឬទេ? សូមអធិស្ឋានថា អ្នកនឹងក្រោកឡើង តយុទ្ធដើម្បីព្រះយេស៊ូវនៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយអ្នកដែលមិនមែនជាគ្រីស្ទបរិសទ័ទាំងនោះ។



